សេចក្តីសង្ខេបអំពីការធានារ៉ាប់រង
OSHC គ្រប់ជ្រុងជ្រោយ។

ខាងក្រោមនេះជាសេចក្តីសង្ខេបអំពីសេវាកម្ម និងការព្យាបាលដែលយើងផ្តល់អត្ថប្រយោជន៍សម្រាប់ការធានារ៉ាប់រងរបស់អ្នក។ សូមអានវា ហើយរក្សាទុកវានៅកន្លែងមានសុវត្ថិភាពសម្រាប់ជាឯកសារយោងនៅពេលអនាគត។ ដើម្បីយល់ដឹងកាន់តែច្បាស់អំពីរបៀបដំណើរការលើការធានារ៉ាប់រងរបស់អ្នក សូមមើលសៀវភៅណែនាំសមាជិក Medibank OSHC របស់អ្នក ឬទាក់ទងមកពួកយើងតាមរយៈលេខ 134 148។

ការធានារ៉ាប់រងសម្រាប់ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ។

ការធានារ៉ាប់រងសម្រាប់ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ អាចជួយចេញថ្លៃចំណាយសម្រាប់សេវា ដែលអ្នកទទួលបាន នៅពេលអ្នកចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងទទួលការព្យាបាលក្នុងនាមជាអ្នកជំងឺឯកជន។

ខាងក្រោមនេះ គឺជាសេវាមន្ទីរពេទ្យដែលទទួលបានការធានារ៉ាប់រង ឬមិនទទួលបានការធានារ៉ាប់រងនៅក្រោមការធានារ៉ាប់រងរបស់អ្នក។

អ្នកនៅតែអាចត្រូវចំណាយប្រាក់ដោយខ្លួនឯងលើសពីចំនួនទឹកប្រាក់ដែលយើងចេញជូន។ មុនពេលកក់ទុកការព្យាបាលរបស់អ្នក សូមទូរសព្ទមកយើងខ្ញុំ ដើម្បីស្វែងយល់អំពីអត្ថប្រយោជន៍ដែលអ្នកអាចរំពឹងថានឹងទទួលបាន និងការចំណាយដោយខ្លួនឯងណាមួយដែលអ្នកអាចនឹងត្រូវចំណាយ។

សេវាកម្មដែលរួមបញ្ចូល ឬមិនរួមបញ្ចូល	
ការស្តារនីតិសម្បទា	✔
សេវាកម្មផ្នែកចិត្តវេជ្ជសាស្ត្រនៅមន្ទីរពេទ្យ	✔
ការថែទាំបន្ទូរោគសញ្ញានិងការឈឺចាប់	✔
ខួរក្បាល និងប្រព័ន្ធសរសៃប្រសាទ	✔
ភ្នែក (មិនរាប់បញ្ចូលជំងឺភ្នែកឡើងបាយ)	✔
ត្រចៀក ច្រមុះ និងបំពង់ក	✔
ក្រពេញអាមីដាល់ ក្រពេញអាដេណូអ៊ីត និងបំពង់ខ្យល់ត្រចៀក	✔
ឆ្អឹង សន្លាក់ និង សាច់ដុំ	✔
ការវះកាត់ស្តារសន្លាក់ឡើងវិញ	✔
តម្រងនោម និងប្លោកនោម	✔
ប្រព័ន្ធបន្តពូជបុរស	✔
ប្រព័ន្ធរំលាយអាហារ	✔
ក្លូន និងខ្នែងពោះវៀន	✔
ការឆ្លុះពិនិត្យប្រព័ន្ធរំលាយអាហារ	✔
រោគស្ត្រី	✔
ការរលូតកូន និងការបញ្ចប់ការមានផ្ទៃពោះ	✔
ការព្យាបាលជំងឺមហារីកដោយប្រើថ្នាំគីមី ការព្យាបាលដោយកាំរស្មី និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ*	✔
ការគ្រប់គ្រងការឈឺចាប់	✔
ស្បែក	✔
ការវះកាត់សុដន់ (ចាំបាច់តាមវេជ្ជសាស្ត្រ)	✔
ការគ្រប់គ្រងជំងឺទឹកនោមផ្អែម (មិនរាប់បញ្ចូលម៉ាស៊ីនបូមអាំងស៊ុយលីន)	✔
ប្រព័ន្ធបេះដូង និងប្រព័ន្ធសរសៃឈាម	✔
សួត និងទ្រូង	✔
ឈាម	✔
ខ្នង ក និងឆ្អឹងខ្នង	✔
ការវះកាត់កែសម្ផស្ស និងការវះកាត់ស្តារឡើងវិញ (ដែលចាំបាច់តាមផ្នែកវេជ្ជសាស្ត្រ)	✔
ការវះកាត់ធ្មេញ^	✔
ការវះកាត់ជើង (ធ្វើឡើងដោយគ្រូពេទ្យវះកាត់ជើងដែលបានចុះបញ្ជី)+	✔
ការដំឡើងឧបករណ៍ជំនួយការស្តាប់	✔
ជំងឺភ្នែកឡើងបាយ	✔
ការវះកាត់ប្តូរសន្លាក់	✔
ការលាងឈាមសម្រាប់ជំងឺខ្សោយតម្រងនោមរ៉ាំរ៉ៃ	✔
ការមានផ្ទៃពោះ និងការសម្រាលកូន	✔
សេវាជំនួយការបន្តពូជ	✘
ការវះកាត់សម្រកទម្ងន់	✔
ម៉ាស៊ីនបូមអាំងស៊ុយលីន	✔
ការគ្រប់គ្រងការឈឺចាប់ដោយប្រើឧបករណ៍	✔
ការសិក្សាអំពីការគេង	✔

តើវាមានន័យដូចម្តេច?

✔ **សេវាដែលរាប់បញ្ចូល**

យើងបង់អត្ថប្រយោជន៍សម្រាប់ថ្លៃស្នាក់នៅមន្ទីរពេទ្យពេញមួយយប់ និងស្នាក់នៅព្យាបាលក្នុងថ្ងៃតែមួយ ការថែទាំកម្រិតធ្ងន់ និងសេវាវេជ្ជសាស្ត្រដែលអាចទទួលបានអត្ថប្រយោជន៍ពី Medicare។

✘ **សេវាដែលមិនបានរាប់បញ្ចូល**

សេវាដែលមិនរាប់បញ្ចូល គឺជាសេវាដែលយើងមិនបង់អត្ថប្រយោជន៍អ្វីសោះ លើសេវានោះ រួមទាំងការស្នាក់នៅមន្ទីរពេទ្យ ឬសេវាវេជ្ជសាស្ត្រណាមួយ។

សេវាថែទាំទូទៅ និងសេវាជំនួយគាំទ្រ

មានសេវាមួយចំនួននៅក្នុងតារាងអត្ថប្រយោជន៍ Medicare (MBS) ដែលនឹងត្រូវបានរួមបញ្ចូលផងដែរ ដើម្បីជួយគាំទ្រដល់សេវានានាក្រោមការធានារ៉ាប់រងនេះ នៅពេលដែលអត្ថប្រយោជន៍ត្រូវបានអនុញ្ញាតឱ្យបង់ជូន។ សេវាទាំងនេះ អាចរួមមានសេវាដូចជា សេវាពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតក្នុងអំឡុងពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ការថតស្កេនមួយចំនួន ការធ្វើតេស្ត និងសេវាប្រើថ្នាំសន្លប់ដែលពាក់ព័ន្ធនឹងការសម្រាកព្យាបាលរបស់អ្នកនៅមន្ទីរពេទ្យ។

សេវារថយន្តសង្គ្រោះបន្ទាន់

យើងនឹងបង់ថ្លៃចំណាយ 100% សម្រាប់សេវារថយន្តសង្គ្រោះបន្ទាន់ដោយគ្មានកំណត់ នៅទូទាំងប្រទេសអូស្ត្រាលី។ សម្រាប់សេវារថយន្តសង្គ្រោះបន្ទាន់ដែលមកជួយអ្នក ឬដឹកជញ្ជូនអ្នកទៅកាន់មន្ទីរពេទ្យ នៅពេលអ្នកត្រូវការការថែទាំកម្រិតយកចិត្តទុកដាក់ខ្លាំងផ្នែកវេជ្ជសាស្ត្រពីអ្នកជំនាញភ្លាមៗ ហើយស្ថានភាពសុខភាពរបស់អ្នកធ្ងន់ធ្ងរដល់កម្រិតដែលមិនអាចដឹកជញ្ជូនតាមមធ្យោបាយផ្សេងបាន។

ផ្នែកគ្រោះថ្នាក់ និងសង្គ្រោះបន្ទាន់

ប្រសិនបើអ្នកត្រូវទៅកាន់ផ្នែកគ្រោះថ្នាក់ និងសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យរដ្ឋ ឬឯកជន យើងនឹងចេញថ្លៃចំណាយ 100% សម្រាប់ 'សេវាមន្ទីរពេទ្យ' ណាមួយដែលមន្ទីរពេទ្យគិតថ្លៃ ដោយមិនគិតថា អ្នកត្រូវបានអនុញ្ញាតឱ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬអត់នោះទេ។

ថ្លៃសេវានេះអាចមិនរួមបញ្ចូលសេវាវេជ្ជសាស្ត្រទាំងអស់ដែលបានផ្តល់ជូនទេ ហើយអ្នកអាចត្រូវចំណាយប្រាក់ដោយខ្លួនឯង ដូចជា សម្រាប់ការថតកាំរស្មីអ៊ិច ការធ្វើតេស្តឈាម និងថ្លៃសេវាណាមួយដែលវេជ្ជបណ្ឌិតគិតលើសពីចំនួនអត្ថប្រយោជន៍ដែលយើងបង់ជូន។

ការធានារ៉ាប់រងសម្រាប់ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ មិនចេញថ្លៃចំណាយសម្រាប់ការព្យាបាលកែសម្ផស្សដែលមិនចាំបាច់តាមផ្នែកវេជ្ជសាស្ត្រទេ។ ក្រោមការធានារ៉ាប់រងរបស់អ្នក យើងបង់អត្ថប្រយោជន៍ក្នុងកម្រិតកំណត់សម្រាប់ថ្លៃឱសថ។ អ្នកអាចមានចំណាយចេញពីហោប៉ៅខ្លួនឯងក្នុងចំនួនច្រើន ប្រសិនបើអ្នកត្រូវការឱសថដែលមានតម្លៃខ្ពស់ ដូចជា ឱសថដែលប្រើក្នុងការព្យាបាលជំងឺមហារីក (ការព្យាបាលជំងឺមហារីក)។

* យើងនឹងចេញថ្លៃចំណាយតែសម្រាប់ការវះកាត់ដែលពាក់ព័ន្ធនឹងជំងឺមហារីក និងទាក់ទងនឹងសេវាដែលទទួលបានការធានារ៉ាប់រងក្រោមការធានារ៉ាប់រងរបស់អ្នកប៉ុណ្ណោះ។

^ សម្រាប់ការវះកាត់ធ្មេញដែលធ្វើឡើងដោយគ្រូពេទ្យធ្មេញជំនួសឱ្យវេជ្ជបណ្ឌិត យើងនឹងចេញអត្ថប្រយោជន៍សម្រាប់តែថ្លៃសេវាមន្ទីរពេទ្យប៉ុណ្ណោះ។ ប្រសិនបើការវះកាត់បានធ្វើឡើងដោយគ្រូពេទ្យ ហើយបានចេញវិក្កយបត្រដោយប្រើលេខសម្គាល់សេវា MBS យើងនឹងបង់អត្ថប្រយោជន៍មួយផ្នែកសម្រាប់ថ្លៃមន្ទីរពេទ្យ និងថ្លៃសេវាវេជ្ជសាស្ត្រ។

\+ សម្រាប់ការវះកាត់ជើងដោយគ្រូពេទ្យឯកទេសជើង យើងនឹងចេញអត្ថប្រយោជន៍សម្រាប់តែថ្លៃសេវាមន្ទីរពេទ្យប៉ុណ្ណោះ។ មិនមានលេខសម្គាល់សេវា MBS សម្រាប់ការវះកាត់ផ្នែកជើងដោយគ្រូពេទ្យឯកទេសជើងទេ។ នេះមានន័យថា យើងក៏មិនផ្តល់អត្ថប្រយោជន៍ណាមួយសម្រាប់ថ្លៃសេវារបស់គ្រូពេទ្យវះកាត់ផ្នែកជើង ក្រោមការធានារ៉ាប់រងសម្រាប់ការសម្រាកព្យាបាលនៅមន្ទីរពេទ្យដែរ ហើយអ្នកអាចត្រូវចំណាយចេញពីហោប៉ៅខ្លួនឯងក្នុងចំនួនច្រើន។

ការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រ។

ការធានារ៉ាប់រងរបស់អ្នករួមបញ្ចូលអត្ថប្រយោជន៍សម្រាប់សេវាវេជ្ជសាស្ត្រដែលផ្តល់ដោយវេជ្ជបណ្ឌិត និងមានរាយក្នុងតារាងអត្ថប្រយោជន៍ Medicare (MBS) របស់រដ្ឋាភិបាល។ MBS គឺជាបញ្ជីសេវាវេជ្ជសាស្ត្រ និងថ្លៃសេវាដែលត្រូវគ្នា។

សម្រាប់សេវាដែលបានរួមបញ្ចូល	
យើងបង់ថ្លៃសេវា MBS 100% សម្រាប់៖	សេវាវេជ្ជសាស្ត្រនៅក្នុងមន្ទីរពេទ្យដែលផ្តល់ជូនជាផ្នែកមួយនៃសេវាដែលបានរួមបញ្ចូល (ឧទាហរណ៍ ថ្លៃសេវាវះកាត់ និងថ្លៃគ្រូពេទ្យឯកទេសខាងថ្នាំសណ្តំ)។
	ការពិគ្រោះយោបល់ជាមួយគ្រូពេទ្យទូទៅ (GP)។
យើងបង់ថ្លៃសេវា MBS 85% សម្រាប់៖	សេវាវេជ្ជសាស្ត្រផ្សេងទៀតដែលផ្តល់ជូនក្រៅមន្ទីរពេទ្យ (ឧទាហរណ៍ ដោយវេជ្ជបណ្ឌិតឯកទេស សេវាពិនិត្យរោគវិទ្យា និងការថតកាំរស្មីអ៊ិច) លើកលែងតែសេវាជំនួយការបន្តពូជ។
	សេវាសុខភាពបំពេញបន្ថែមដែលត្រូវបានចេញវិក្កយបត្រដោយប្រើលេខសម្គាល់សេវា MBS (ឧទាហរណ៍ ការពិនិត្យភ្នែក និងសេវាដែលពាក់ព័ន្ធនឹងផែនការគ្រប់គ្រងជំងឺរ៉ាំរ៉ៃ និងសុខភាពផ្លូវចិត្ត)។

អ្នកត្រូវបង់ចំនួនទឹកប្រាក់ខុសគ្នាណាមួយរវាងអត្ថប្រយោជន៍ដែលយើងបង់ និងថ្លៃសេវាជាក់ស្តែងដែលវេជ្ជបណ្ឌិតគិតថ្លៃ។

ថ្នាំពេទ្យតាមវេជ្ជបញ្ជា (ឱសថ)

OSHC គ្រប់ជ្រុងជ្រោយផ្តល់អត្ថប្រយោជន៍ចំពោះការចំណាយលើថ្នាំពេទ្យតាមវេជ្ជបញ្ជា (ឱសថ) ដែលមានសិទ្ធិទទួលបាន។ អ្នកនឹងត្រូវបង់ចំណែកថ្លៃចំណាយសម្រាប់ថ្នាំតាមវេជ្ជបញ្ជានីមួយៗដែលមានសិទ្ធិទទួលបាន មុនពេលយើងបង់អត្ថប្រយោជន៍ណាមួយ។

សម្រាប់ថ្នាំដែលមានសិទ្ធិទទួលបានតាមវេជ្ជបញ្ជា	
ការចូលរួមរបស់សមាជិក	$30
ចំនួនទឹកប្រាក់ដែលយើងនឹងបង់ (អតិបរមាសម្រាប់ទំនិញមួយមុខ)	ថ្លៃចំណាយ 100%
ចំនួនកំណត់ប្រចាំឆ្នាំ - សមាជិកភាពបុគ្គល	$1,000
ចំនួនកំណត់ប្រចាំឆ្នាំ -សមាជិកភាពគូស្វាមីភរិយា/គ្រួសារ	$1,000 សម្រាប់សមាជិកម្នាក់ / $2,000 សម្រាប់សមាជិកភាពមួយ

- ប្រសិនបើថ្លៃថ្នាំតាមវេជ្ជបញ្ជាខ្ពស់ជាងចំនួនអត្ថប្រយោជន៍ដែលយើងបង់ អ្នកត្រូវបង់ចំនួនខុសគ្នានោះដោយខ្លួនឯង។
- អត្ថប្រយោជន៍អាចបង់សម្រាប់ឱសថដែលត្រូវការវេជ្ជបញ្ជាប៉ុណ្ណោះ ដែលចេញវេជ្ជបញ្ជាដោយវេជ្ជបណ្ឌិត (វេជ្ជបណ្ឌិតទូទៅ (GP) ឬគ្រូពេទ្យឯកទេស) ដើម្បីព្យាបាលជំងឺ របួស ឬស្ថានភាពសុខភាព។
- យើងមិនបង់អត្ថប្រយោជន៍ជួយថ្លៃឱសថដែលបានចេញវេជ្ជបញ្ជាសម្រាប់គោលបំណងកែសម្ផស្ស ឬឱសថតាមវេជ្ជបញ្ជាដែលពាក់ព័ន្ធនឹងសេវាដែលបានដកចេញពីការធានារ៉ាប់រងនោះទេ។

វាជារឿងសំខាន់ដែលត្រូវកត់សម្គាល់ថា អ្នកអាចមានការចំណាយផ្ទាល់ខ្លួនច្រើន ប្រសិនបើអ្នកត្រូវការការព្យាបាលដែលប្រើប្រាស់ឱសថដែលមានតម្លៃខ្ពស់ (ឧទាហរណ៍៖ ការព្យាបាលជំងឺមហារីក)។

(បន្តនៅទំព័របន្ទាប់)

ជាមួយនឹង OSHC គ្រប់ជ្រុងជ្រោយ អ្នកអាចចូលប្រើប្រាស់មុខងារ និងសេវាកម្មបន្ថែម ដើម្បីផ្តល់ការគាំទ្របន្ថែមបន្តិចបន្តួច។

ជំនួយគាំទ្រសុខភាពផ្លូវចិត្ត

ការធានារ៉ាប់រងរបស់អ្នករួមបញ្ចូលអត្ថប្រយោជន៍ជួយបង់ថ្លៃសេវាចិត្តវិទ្យា និងសេវាប្រឹក្សាយោបល់ ដែលទទួលបានពីអ្នកផ្តល់សេវាដែលត្រូវបានទទួលស្គាល់ និងត្រូវបានគិតថ្លៃជាឯកជន (មានន័យថា មិនប្រើលេខសម្គាល់សេវា MBS)។

	ការពិគ្រោះយោបល់ជាមួយអ្នកចិត្តសាស្ត្រ	ការពិគ្រោះយោបល់ជាមួយអ្នកប្រឹក្សា/ បុគ្គលិកសង្គមកិច្ចផ្នែកសុខភាពផ្លូវចិត្ត
ចំនួនទឹកប្រាក់ដែលយើងនឹងបង់ (អតិបរមា សម្រាប់ការពិគ្រោះយោបល់មួយលើក)	$100	$70
ចំនួនកំណត់ប្រចាំឆ្នាំ - សមាជិកភាពបុគ្គល	$200	
ចំនួនកំណត់ប្រចាំឆ្នាំ - សមាជិកភាពសម្រាប់គូស្វាមីភរិយា/គ្រួសារ	$400	

សូមមើលផ្នែក «ការធានារ៉ាប់រងវេជ្ជសាស្ត្រ» នៅទំព័រ 2 ដើម្បីស្វែងយល់ពីរបៀបដែលយើងរួមចំណែកបង់ថ្លៃសេវាសុខភាពផ្លូវចិត្តដែលបានចេញវិក្កយបត្រដោយប្រើលេខសម្គាល់សេវា MBS (ឧទាហរណ៍ សេវាក្រោមផែនការគ្រប់គ្រងសុខភាពផ្លូវចិត្ត)។

ការធ្វើមាតុភូមិនិវត្តន៍

ប្រសិនបើអ្នក ឬបុគ្គលណាម្នាក់ដែលបានដាក់បញ្ចូលក្នុងសមាជិកភាពរបស់អ្នក ទទួលរងពិការភាពធ្ងន់ធ្ងរដែលផ្លាស់ប្តូរជីវិតយ៉ាងខ្លាំង ឬមានស្ថានភាពសុខភាពធ្ងន់ធ្ងរ តាមការវាយតម្លៃរបស់យើង ហើយត្រូវការវិលត្រឡប់ទៅប្រទេសកំណើតវិញ យើងអាចរៀបចំ និងបង់ថ្លៃធ្វើដំណើរក្នុងកម្រិតសមរម្យ ដោយមានការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រដ៏សមស្រប (រហូតដល់អតិបរមា $100,000)។

ក្នុងករណីដ៏អកុសលដែលមានមរណភាពកើតឡើង យើងនឹងបង់ថ្លៃដឹកសពរបស់អ្នក ឬបុគ្គលផ្សេងទៀតដែលស្ថិតក្រោមសមាជិកភាពរបស់អ្នក ត្រឡប់ទៅប្រទេសកំណើតរបស់បុគ្គលនោះវិញ ក្នុងកម្រិតអតិបរមា $10,000។

ការផ្តល់អត្ថប្រយោជន៍សម្រាប់ការបញ្ជូនត្រឡប់ទៅប្រទេសកំណើតណាមួយ គឺអាស្រ័យលើការសម្រេចរបស់យើង ហើយអត្ថប្រយោជន៍នេះ អាចបង់ជូនសមាជិកម្នាក់ៗបានតែមួយលើកប៉ុណ្ណោះក្នុងមួយជីវិត។

រយៈពេលរង់ចាំ 12 ខែ អនុវត្តតែចំពោះការបញ្ជូនសមាជិកដែលមានជំងឺ ឬរងរបួសត្រឡប់ទៅប្រទេសកំណើតវិញ ដោយសារមូលហេតុដូចខាងក្រោម៖

- ស្ថានភាពជំងឺដែលមានរួចជាស្រេច
- ការមានផ្ទៃពោះ និងការសម្រាលកូន។

រយៈពេលរង់ចាំនេះនឹងត្រូវលើកលែង ប្រសិនបើវេជ្ជបណ្ឌិតបញ្ជាក់ថា អ្នកត្រូវការការព្យាបាលបន្ទាន់ ហើយយើងយល់ស្របនឹងការបញ្ជាក់នោះ។

លក្ខខណ្ឌត្រូវបានអនុវត្ត សូមហៅទូរសព្ទមកលេខ **134 148** ដើម្បីទទួលព័ត៌មានបន្ថែម។

តើពាក្យ «សពរបស់អ្នកស្លាប់» មានន័យដូចម្តេច? សម្រាប់គោលបំណងនៃអត្ថប្រយោជន៍សម្រាប់ការបញ្ជូនត្រឡប់ទៅប្រទេសកំណើតវិញ «សព» សំដៅលើរាងកាយរបស់បុគ្គលដែលបានទទួលមរណភាព។ នេះមិនរាប់បញ្ចូលការបូជាសព ឬធាតុអដ្ឋិរបស់បុគ្គលដែលបានស្លាប់នោះទេ។

អត្ថប្រយោជន៍សម្រាប់សមាជិកគ្រួសារស្នាក់នៅក្នុងមន្ទីរពេទ្យ (ថ្លៃស្នាក់នៅ)

ប្រសិនបើអ្នក ឬបុគ្គលណាម្នាក់ដែលស្ថិតក្រោមសមាជិកភាពរបស់អ្នក ត្រូវបានអនុញ្ញាតឱ្យចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យសម្រាប់សេវាដែលរួមបញ្ចូលក្នុងការធានារ៉ាប់រង ហើយដៃគូ សមាជិកគ្រួសារជិតស្និទ្ធ អ្នកថែទាំ ឬសាច់ញាតិជិតបំផុតរបស់បុគ្គលនោះ (‘អ្នកស្នាក់នៅកំដរអ្នកជំងឺ’) ត្រូវការស្នាក់នៅជាមួយបុគ្គលនោះក្នុងមន្ទីរពេទ្យ យើងនឹងរួមចំណែកបង់ថ្លៃកន្លែងស្នាក់នៅ និងអាហារដែលមន្ទីរពេទ្យគិតថ្លៃសម្រាប់អ្នកស្នាក់នៅអមអ្នកជំងឺនោះ រហូតដល់ $150 ក្នុងការចូលសម្រាកព្យាបាលមួយលើក។

(បន្តនៅទំព័របន្ទាប់)

? អ្វីដែលអ្នកត្រូវដឹងអំពី OSHC របស់អ្នក។

ចំនួនកំណត់ប្រចាំឆ្នាំ

កម្រិតអតិបរមាប្រចាំឆ្នាំ គឺជាចំនួនអត្ថប្រយោជន៍អតិបរមាដែលអាចបង់ជូនសម្រាប់សមាជិកម្នាក់ៗ និង/ឬសម្រាប់សមាជិកភាពទាំងមូល ក្នុងរយៈពេលមួយឆ្នាំប្រតិទិន (ចាប់ពីថ្ងៃទី 1 ខែមករា ដល់ថ្ងៃទី 31 ខែធ្នូ)។

រយៈពេលរង់ចាំ

រយៈពេលរង់ចាំត្រូវបានអនុវត្ត នៅពេលអ្នកចូលជាសមាជិករបស់ Medibank ឬផ្លាស់ប្តូរការធានារ៉ាប់រងរបស់អ្នក ដើម្បីបញ្ចូលសេវាថ្មី ឬសេវាដែលបានដំឡើងកម្រិត។ យើងនឹងមិនបង់អត្ថប្រយោជន៍សម្រាប់សម្ភារៈណាមួយដែលបានទិញ ឬសេវាណាមួយដែលបានទទួល ក្នុងអំឡុងពេលដែលអ្នកកំពុងបំពេញរយៈពេលរង់ចាំឡើយ។

កំពុងផ្លាស់ប្តូរពីក្រុមហ៊ុនធានារ៉ាប់រងសុខភាពផ្សេងទៀតមែនទេ?

ប្រសិនបើអ្នកកំពុងផ្លាស់មកពី OSHC របស់ក្រុមហ៊ុនធានារ៉ាប់រងសុខភាពអូស្ត្រាលីផ្សេងទៀត មិនត្រូវមានគម្លាតរវាងកាលបរិច្ឆេទបញ្ចប់នៃការធានារ៉ាប់រងមុនរបស់អ្នក និងកាលបរិច្ឆេទចាប់ផ្តើមនៃសមាជិកភាព Medibank OSHC របស់អ្នកឡើយ។

ប្រសិនបើការធានារ៉ាប់រងមុនរបស់អ្នកមិនមែនជា OSHC ទេ នោះប្រសិនបើអ្នកបានចូលរួមជាមួយ Medibank OSHC ក្នុងរយៈពេលពីរខែបន្ទាប់ពីចាកចេញពីក្រុមហ៊ុនធានារ៉ាប់រងអូស្ត្រាលីមុនរបស់អ្នក ជាទូទៅអ្នកនឹងមិនចាំបាច់កក់រយៈពេលរង់ចាំឡើងវិញនៅ Medibank ទេ។

រយៈពេលរង់ចាំ	
គ្មាន	សេវារថយន្តសង្គ្រោះបន្ទាន់។
	សេវាវេជ្ជសាស្ត្រក្រៅមន្ទីរពេទ្យ (ឧទាហរណ៍ ការពិគ្រោះជាមួយគ្រូពេទ្យទូទៅ (GP))។
	ថ្នាំពេទ្យតាមវេជ្ជបញ្ជា។
	សេវាជំនួយគាំទ្រសុខភាពផ្លូវចិត្ត។
	សេវាផ្នែកចិត្តសាស្ត្រនៅមន្ទីរពេទ្យ (រួមទាំងសេវាសម្រាប់ស្ថានភាពជំងឺដែលមានពីមុន)។
	ការព្យាបាលសម្រាប់ជំងឺដែលត្រូវការការសម្រាកព្យាបាលនៅមន្ទីរពេទ្យ ហើយមិនបានចាត់ទុកថា ជាជំងឺដែលមានពីមុននោះទេ។
	ការមានផ្ទៃពោះ និងការសម្រាលកូន ព្រមទាំងសេវារលូតកូន និងការបញ្ចប់ការមានផ្ទៃពោះ (គោលនយោបាយដែលមានរយៈពេល 2 ឆ្នាំ ឬច្រើនជាងនេះ*)
12 ខែ	**ស្ថានភាពជំងឺដែលមានរួចជាស្រេច** ជំងឺ អាការៈឈឺ ឬស្ថានភាពសុខភាពណាមួយ ដែលតាមយោបល់របស់វេជ្ជបណ្ឌិតដែលយើងបានចាត់តាំង មានសញ្ញា ឬរោគសញ្ញាកើតមាននៅពេលណាមួយក្នុងអំឡុងពេល 6 ខែ គិតត្រឹមថ្ងៃដែលអ្នកចាប់ផ្តើមទទួលបានការធានារ៉ាប់រងក្រោមបណ្ណធានារ៉ាប់រង ឬថ្ងៃដែលអ្នកបានផ្លាស់ប្តូរការធានារ៉ាប់រងរបស់អ្នក។
	ការមានផ្ទៃពោះ និងការសម្រាលកូន - សេវានៅក្នុងមន្ទីរពេទ្យ និងក្រៅមន្ទីរពេទ្យ (គោលនយោបាយដែលមានរយៈពេលតិចជាង 2 ឆ្នាំ*)

***ព័ត៌មានសំខាន់អំពីរយៈពេលរង់ចាំដែលទាក់ទងនឹងការមានផ្ទៃពោះ** រយៈពេលនៃគោលនយោបាយ មានន័យថា រយៈពេលសរុបនៃការធានារ៉ាប់រងសុខភាពសម្រាប់និស្សិតបរទេសដែលបានទិញក្រោមគោលនយោបាយរបស់អ្នក ដោយផ្អែកលើរយៈពេលទិដ្ឋាការនិស្សិតរបស់អ្នក។ ក្នុងករណីដែលរយៈពេលនៃបណ្ណសន្យាធានារ៉ាប់រងរបស់អ្នកមានរយៈពេល 2 ឆ្នាំ ឬលើសពីនេះ នឹងមិនមានរយៈពេលរង់ចាំសម្រាប់ការមានផ្ទៃពោះ និងការសម្រាលកូន ព្រមទាំងស្ថានភាពជំងឺដែលមានពីមុនពាក់ព័ន្ធនឹងការរលូតកូន និងការបញ្ចប់ការមានផ្ទៃពោះនោះទេ។

ការលើកលែងរយៈពេលរង់ចាំសម្រាប់ការព្យាបាលបន្ទាន់

ជាទូទៅ អត្ថប្រយោជន៍នឹងមិនបានទូទាត់សម្រាប់សេវា ឬសម្ភារៈណាមួយដែលអ្នកបានទទួល ក្នុងអំឡុងពេលដែលអ្នកកំពុងបំពេញរយៈពេលរង់ចាំឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ លក្ខខណ្ឌតម្រូវឱ្យរង់ចាំនឹងត្រូវបានលើកលែង ប្រសិនបើវេជ្ជបណ្ឌិតព្យាបាលរបស់អ្នកបញ្ជាក់ថា អ្នកចាំបាច់ត្រូវទទួលការព្យាបាលបន្ទាន់ ហើយយើងយល់ព្រមថា ការព្យាបាលនោះចាំបាច់។

(បន្តនៅទំព័របន្ទាប់)

ទាញយកអត្ថប្រយោជន៍ច្រើនបំផុតពី OSHC របស់អ្នក។

ការជ្រើសរើសមន្ទីរពេទ្យ

យើងមានកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យឯកជន និងមជ្ឈមណ្ឌលវះកាត់ប្រចាំថ្ងៃភាគច្រើននៅក្នុងប្រទេសអូស្ត្រាលី ដែលហៅថា មន្ទីរពេទ្យជម្រើសរបស់សមាជិក។ សម្រាប់សេវាដែលទទួលបានការធានារ៉ាប់រងនៅក្នុងមន្ទីរពេទ្យជម្រើសរបស់សមាជិក យើងនឹងបង់អត្ថប្រយោជន៍សម្រាប់ថ្លៃស្នាក់នៅមន្ទីរពេទ្យពេញមួយយប់ និងស្នាក់នៅព្យាបាលក្នុងថ្ងៃតែមួយក្នុងបន្ទប់រួម ឬបន្ទប់ឯកជន ការថែទាំកម្រិតធ្ងន់ ថ្លៃបន្ទប់វះកាត់ និងថ្លៃបន្ទប់សម្រាលកូន។ ជាទូទៅ អ្នកនឹងទទួលបានតម្លៃកាន់តែប្រសើរ ប្រសិនបើអ្នកទៅរកអ្នកផ្តល់សេវាមួយក្នុងចំណោមអ្នកផ្តល់សេវាទាំងនេះ។

ដើម្បីស្វែងរកមន្ទីរពេទ្យជម្រើសរបស់សមាជិក ដែលនៅជិតអ្នកបំផុត សូមចូលទៅកាន់ **medibankoshc.com.au/find-provider**។ មន្ទីរពេទ្យជម្រើសរបស់សមាជិកអាចមានការផ្លាស់ប្តូរពីមួយពេលទៅមួយពេល ហើយមិនមាននៅគ្រប់តំបន់ទាំងអស់នោះទេ។

ប្រសិនបើអ្នកទទួលការព្យាបាលនៅមន្ទីរពេទ្យឯកជនដែលមិនមែនជាជម្រើសរបស់សមាជិក សម្រាប់សេវាដែលទទួលបានការធានារ៉ាប់រង ជាទូទៅ យើងនឹងបង់អត្ថប្រយោជន៍ក្នុងចំនួនទាបជាង ហើយអ្នកអាចត្រូវចំណាយប្រាក់ដោយខ្លួនឯងក្នុងចំនួនច្រើន។

កន្លែងដែលអ្នកត្រូវបានគេចាត់ទុកដូចជា **អ្នកជំងឺឯកជនម្នាក់នៅក្នុងមន្ទីរពេទ្យរដ្ឋ** សម្រាប់សេវាដែលរួមបញ្ចូល យើងនឹងបង់ថ្លៃស្នាក់នៅមួយយប់ និងថ្លៃដដែលក្នុងបន្ទប់រួម ឬបន្ទប់ឯកជន ថ្លៃថែទាំក្នុងផ្នែកសង្គ្រោះបន្ទាន់ ថ្លៃបន្ទប់សម្ភព និងថ្លៃសេវាផ្នែកសម្ភព។ យើងក៏នឹងចេញថ្លៃសេវាប្រើប្រាស់មូលដ្ឋានរបស់ផ្នែកគ្រោះថ្នាក់ និងសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យសាធារណៈផងដែរ ព្រមទាំងបង់អត្ថប្រយោជន៍សម្រាប់សេវាវេជ្ជសាស្ត្រដែលអ្នកទទួលបាននៅផ្នែកគ្រោះថ្នាក់ និងសង្គ្រោះបន្ទាន់ ឬផ្នែកអ្នកជំងឺក្រៅរបស់មន្ទីរពេទ្យទាំងនោះ។

សិទ្ធិជ្រើសរើសវេជ្ជបណ្ឌិត ឬគ្រូពេទ្យឯកទេសព្យាបាលផ្ទាល់ខ្លួន

អ្នកអាចជ្រើសរើសគ្រូពេទ្យ ឬវេជ្ជបណ្ឌិតជំនាញផ្ទាល់ខ្លួនបាន នៅពេលដែលអ្នកទទួលការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យក្នុងនាមជាអ្នកជំងឺឯកជន។

ឧបករណ៍វេជ្ជសាស្ត្រ និងផលិតផលជាលិកាមនុស្ស

សម្រាប់សេវាដែលទទួលបានការធានារ៉ាប់រង យើងនឹងបង់អត្ថប្រយោជន៍អប្បបរមា ដូចដែលបានរាយក្នុងបញ្ជីកំណត់សម្រាប់ឧបករណ៍វេជ្ជសាស្ត្រ និងផលិតផលជាលិកាមនុស្សរបស់រដ្ឋាភិបាលអូស្ត្រាលី។

បណ្តាញទំនាក់ទំនងជំនួយ និងសុខភាពនិស្សិត 24/7

ត្រូវការការគាំទ្របន្ថែមទេ? អ្នកអាចទូរសព្ទទៅលេខ 1800 887 283 នៅពេលណាក៏បាន ទាំងថ្ងៃទាំងយប់^ ដើម្បីទទួលបានដំបូន្មានសុខភាពពីគិលានុបដ្ឋាយិកាដែលបានចុះបញ្ជីសេវាប្រឹក្សា ដំបូន្មានផ្នែកច្បាប់បន្ទាន់ ជំនួយឯកសារធ្វើដំណើរ សេវាបកប្រែ និងសេវាផ្សេងៗទៀត។

គ្រប់គ្រងគណនីរបស់អ្នកតាមអ៊ីនធឺណិតដោយប្រើសេវាសមាជិកអនឡាញ (OMS)

កម្មវិធី Medibank OSHC OMS គឺជាមធ្យោបាយងាយស្រួលក្នុងការគ្រប់គ្រងសមាជិកភាពរបស់អ្នកតាមអ៊ីនធឺណិត។

អ្នកអាចដាក់ពាក្យទាមទារសំណងសម្រាប់សេវាវេជ្ជសាស្ត្រភាគច្រើន មើល និងធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតអំពីសមាជិកភាព មើលប្រវត្តិការទាមទារសំណង បន្តការធានារ៉ាប់រងរបស់អ្នក ស្វែងរកអ្នកផ្តល់សេវាវេជ្ជសាស្ត្រដែលទទួលការទូទាត់ដោយផ្ទាល់ ឬមន្ទីរពេទ្យជម្រើសរបស់សមាជិក និងអ្វីៗជាច្រើនទៀត។

ល្អបំផុត គ្រាន់តែចំណាយពេលពីរនាទីប៉ុណ្ណោះដើម្បីបង្កើតគណនីសម្រាប់ OMS នៅលើគេហទំព័រ **medibankoshc.com.au**

កម្មវិធី Medibank OSHC

រចនាឡើងសម្រាប់និស្សិតអន្តរជាតិ កម្មវិធី Medibank OSHC អាចជួយអ្នកគ្រប់គ្រងសមាជិកភាព Medibank OSHC របស់អ្នក

- ពិនិត្យមើលព័ត៌មានលម្អិតអំពីការធានារ៉ាប់រងរបស់អ្នក
- ធ្វើការទាមទារសំណងសម្រាប់សេវាកម្មវេជ្ជសាស្ត្រភាគច្រើន
- ស្វែងរកគ្រូពេទ្យដែលគិតថ្លៃដោយផ្ទាល់នៅក្បែរ
- ពិគ្រោះយោបល់តាមអ៊ីនធឺណិតជាមួយវេជ្ជបណ្ឌិតដែលមានវឌ្ឍនភាព
- ចូលប្រើកាតសមាជិកឌីជីថល Medibank របស់អ្នក
- បកប្រែមុខងារមួយចំនួននៃប្រព័ន្ធទៅជាភាសាចិនអក្សរកាត់

^ សេវាមួយចំនួនអាចមិនមានផ្តល់ជូន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ ហើយអាចតម្រូវឱ្យមានការហៅត្រឡប់វិញ។

(បន្តនៅទំព័របន្ទាប់)

សូមទាក់ទងមកយើងជាមុនសិន។

ទាក់ទងជាមួយពួកយើង

នៅពេលដែលអាចធ្វើទៅបាន មុនពេលកក់ ឬទទួលការព្យាបាល អ្នកគួរតែទូរសព្ទមកយើងជានិច្ច ដើម្បីសាកសួរអំពីអត្ថប្រយោជន៍ដែលអ្នកអាចរំពឹងថា នឹងទទួលបាន និងការចំណាយដោយខ្លួនឯងណាមួយដែលអ្នកអាចនឹងត្រូវចំណាយ។

វាក៏ជាការល្អផងដែរ ក្នុងការបញ្ជាក់អំពីការចំណាយដោយខ្លួនឯងណាមួយ មុនពេលចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ជាមួយមន្ទីរពេទ្យ និងវេជ្ជបណ្ឌិត (រួមទាំងគ្រូពេទ្យវះកាត់ ជំនួយការគ្រូពេទ្យវះកាត់ និងគ្រូពេទ្យផ្នែកថ្នាំសន្លប់)។

ព័ត៌មានសំខាន់ៗ។

ប្រសិនបើនៅពេលណាមួយ អ្នកទទួលបានសិទ្ធិពេញលេញក្នុងការទទួលបានអត្ថប្រយោជន៍ពី Medicare ឬស្ថានភាពទិដ្ឋាការរបស់អ្នកមានការផ្លាស់ប្តូរ (ឧទាហរណ៍ អ្នកអនុញ្ញាតឱ្យមានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍ ឬទទួលបានទិដ្ឋាការបណ្តោះអាសន្នសម្រាប់និស្សិតបញ្ចប់ការសិក្សា 485) ការធានារ៉ាប់រងនេះអាចលែងសមស្របសម្រាប់អ្នកទៀតហើយ។ សូមជូនដំណឹងមកពួកយើងតាមរយៈ **134 148** ប្រសិនបើស្ថានភាពរបស់អ្នកមានការផ្លាស់ប្តូរ។

សេចក្តីសង្ខេបអំពីការធានារ៉ាប់រងនេះអាចធ្វើបច្ចុប្បន្នភាពពីពេលមួយទៅពេលមួយ។ អ្នកអាចទាញយកកំណែចុងក្រោយបំផុតពីសេវាសមាជិកអនឡាញរបស់អ្នកនៅលើគេហទំព័រ **medibankoshc.com.au**

របៀបស្វែងរកព័ត៌មានបន្ថែម។

- សូមហៅទៅលេខ **134 148** (**+613 9862 1095** ពីក្រៅប្រទេសអូស្ត្រាលី)
- WhatsApp **+61 3 9862 1345**
- ដោយផ្ទាល់នៅហាង Medibank ក្នុងតំបន់របស់អ្នក
- សារតាមបណ្តាញ **medibankoshc.com.au/contact-us**

ព័ត៌មាននេះមានសុពលភាពគិតត្រឹមខែឧសភា ឆ្នាំ 2026 ហើយអាចមានការផ្លាស់ប្តូរពីពេលមួយទៅពេលមួយ។ វាអនុវត្តចំពោះតែ OSHC គ្រប់ជ្រុងជ្រោយរបស់ Medibank ប៉ុណ្ណោះ។
ប្រសិនបើអ្នកចង់ស្វែងរកព័ត៌មានអំពីកញ្ចប់ធានារ៉ាប់រងណាមួយរបស់យើង សូមទាក់ទងមកកាន់ពួកយើងតាមរយៈលេខ 134 148។
បណ្ណសន្យារ៉ាប់រងនៅក្នុងផលិតផលនេះស្ថិតក្រោមមូលនិធិអត្ថប្រយោជន៍សុខភាពរបស់ក្រុមហ៊ុន Medibank Private Limited។
Medibank Private Limited ABN 47 080 890 259